មជ្ឈមណ្ឌលឯកសារកម្ពុជា

# កម្មវិធីវិទ្យុសហគមន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា

## សម្លេងយុត្តិធម៌៖ អំពើប្រល័យពូជសាសន៍ និងការអត់ឃ្លាននៅក្នុងរបបខ្មែរក្រហម

## វគ្គទី៩

## ប្រធានបទ៖ ច្បាប់ស្ដីអំពីសិទ្ធិមនុស្ស

*ដោយ ៖ វ៉ែនឌុល ឌឹហ្វាល់កូ*

*ជាមួយនឹង ម៉ែន ពិចិត្រ និង លន់ ដាលីន*

*អានដោយ ៖ ឌី ខាំបូលី និង កន ពេញសំណាង*

*សហការជាមួយបន្ទប់ថតសម្លេងរបស់ស្ថានីយវិទ្យុផ្សាយសម្លេងសហរដ្ឋអាមេរិក-រាជធានីភ្នំពេញ*

*ខែវិច្ឆិកា ឆ្នាំ២០១៣*

*ជម្រាបសួរប្រិយមិត្តអ្នកស្ដាប់កម្មវិធីវិទ្យុសហគមន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាទីមេត្រី! នេះគឺជាការផ្សាយវគ្គទី៩ ក្នុងចំណោមការផ្សាយទាំង១០វគ្គនៃកម្មវិធីវិទ្យុរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលពិនិត្យទៅលើទិដ្ឋភាពប្រវត្តិសាស្រ្ត និងច្បាប់ផ្សេងៗទាក់ទងនឹងការអត់ឃ្លានដែលបានកើតមានឡើងនៅក្នុងប្រទេសកម្ពុជាក្នុងរបបខ្មែរក្រហមចន្លោះពី ឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩។ គោលបំណងសំខាន់របស់កម្មវិធីវិទ្យុនេះ គឺដើម្បីផ្សព្វផ្សាយឲ្យប្រជាជនកម្ពុជាទាំងអស់បានដឹងច្បាស់អំពីសាច់រឿងផ្ទាល់ខ្លួនរបស់ជនរងគ្រោះដែលពាក់ព័ន្ធនឹងការអត់ឃ្លាន និងជំរុញឲ្យមានការចូលរួមនៅក្នុងដំណើរការស្វែងរកយុត្តិធម៌។*

*ប្រសិនបើប្រិយមិត្តអ្នកស្ដាប់ចង់ចូលរួមផ្ដល់ជាមតិយោបល់ សួរសំណួរ ឬមានចម្ងល់ផ្សេងៗនៅក្នុងកម្មវិធីសូមសរសេរជាលិខិតផ្ញើមកកាន់ លោក ម៉ែន ពិចិត្រ អ្នករៀបចំកម្មវិធីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលមានអាសយដ្ឋានផ្ទះលេខ ៦៦ មហាវិថីព្រះសីហនុ រាជធានីភ្នំពេញ ឬប្រអប់ សំបុត្រលេខ ១១១០ រាជធានីភ្នំពេញ ឬទំនាក់ទំនងតាមរយៈទូរស័ព្ទលេខ ០២៣-២១១-៨៧៥ ឬទូរសារលេខ ០២៣-២១០-៣៥៨។ កម្មវិធីរបស់យើងខ្ញុំចាក់ផ្សាយរៀងរាល់ថ្ងៃអាទិត្យតាមរយៈវិទ្យុដូចខាងក្រោម។ វគ្គនីមួយៗនឹងត្រូវចាក់ផ្សាយចំនួនបួនដងក្នុងមួយខែ។ រៀងរាល់ដើមខែ យើងខ្ញុំនឹងលើកយកវគ្គថ្មីមកចាក់ផ្សាយជូនប្រិយមិត្តអ្នកស្ដាប់។ ចំពោះប្រិយមិត្តអ្នកស្ដាប់ដែលរស់នៅរាជធានីភ្នំពេញ និង ខេត្តដែលនៅជាប់នឹងរាជធានីភ្នំពេញអាចស្ដាប់កម្មវិធីវិទ្យុសហគមន៍របស់យើងខ្ញុំ តាមរយៈវិទ្យុជាតិកម្ពុជា* FM105.75 MHz *រាជធានីភ្នំពេញ វេលាម៉ោង ៩ព្រឹក*

និង ម៉ោង៧និង៣០នាទីល្ងាច ។ នៅខេត្តកំពត តាមរយៈ វិទ្យុខេត្តកំពត FM93.25 វេលា ម៉ោង ៧ព្រឹក និង ម៉ោង៧ល្ងាច ។ នៅខេត្តព្រះវិហារ តាមរយៈ វិទ្យុខេត្តព្រះវិហារ FM99 វេលា ម៉ោង ៧និង៣០នាទីព្រឹក និងម៉ោង៤រសៀល ។ នៅខេត្តបាត់ដំបង តាមរយៈវិទ្យុខេត្ត បាត់ដំបង FM 103.25 វេលាម៉ោង ៨ព្រឹក និងម៉ោង៤រសៀល ។

ការផ្សាយនៅក្នុងវគ្គមុនៗ យើងបានលើកឡើងអំពីបញ្ហាផ្សេងៗដែលពាក់ព័ន្ធនឹងការអត់ឃ្លានគ្រោះទុរភិក្ស និងច្បាប់ឧក្រិដ្ឋកម្មអន្តរជាតិ ។ ដោយឡែក នៅក្នុងការផ្សាយវគ្គទី៩នេះ យើងខ្ញុំផ្តោតទៅលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងបញ្ហាពាក់ព័ន្ធផ្សេងៗ ។

## សេចក្តីផ្តើម : តើច្បាប់សិទ្ធិមនុស្សអន្តរជាតិគឺជាអ្វី?

ពាក្យថា "សិទ្ធិមនុស្ស" ត្រូវបានយកមកប្រើប្រាស់នៅក្នុងស្ថានភាព និងបរិបទផ្សេងៗគ្នា ។ ជាឧទាហរណ៍ នៅពេលដែលមានរឿងរ៉ាវអ្វីមួយកើតឡើងទៅលើបុគ្គលណាម្នាក់ ដែលទង្វើនោះត្រូវបានមើលឃើញថាមិនមានភាពត្រឹមត្រូវ ឬយុត្តិធម៌ ជនដែលទទួលរង ឬអង្គភាពផ្សេងៗដែលពាក់ព័ន្ធដូចជាអង្គការក្រៅរដ្ឋាភិបាលជាដើម តែងតែនិយាយថា ទង្វើនោះគឺជាការរំលោភសិទ្ធិមនុស្ស ។ ភាពអយុត្តិធម៌បែបនេះនៅតែបន្តកើតឡើងជាប្រចាំនៅទូទាំងសកលលោក ក៏ដូចជានៅប្រទេសកម្ពុជាដូច្នេះដែរ ។ នៅក្នុងកាលៈទេសៈមួយចំនួន ពាក្យ "សិទ្ធមនុស្ស" ត្រូវបានអ្នកនយោបាយប្រើដើម្បីបញ្ឈាក់ពីបុព្វហេតុជាក់លាក់ណាមួយ ។ ការប្រើប្រាស់ពាក្យ "សិទ្ធមនុស្ស" ដោយឡែកៗពីគ្នាបានឆ្លុះបញ្ចាំងឲ្យឃើញពីភាពស្មុគស្មាញនៃច្បាប់ ដែលត្រូវបានយកមកប្រើប្រាស់ ដើម្បីបង្កើតច្បាប់សិទ្ធិមនុស្សអន្តរជាតិ ។ បើតាមផ្លូវច្បាប់ ច្បាប់សិទ្ធិមនុស្ស គឺសំដៅដល់ "សេចក្តីថ្លៃថ្នូរ" មូលដ្ឋានរបស់បុគ្គលគ្រប់រូប ដែលបុគ្គលម្នាក់ៗទទួលបានការការពារប្រកបដោយសីលធម៌ និងសមធម៌ ។ ប៉ុន្តែការកំណត់លក្ខណៈសម្បត្តិឲ្យបានត្រឹមត្រូវ និងជាក់លាក់ ត្រូវតែធ្វើឡើងដើម្បីការពារសេចក្តីថ្លៃថ្នូររបស់មនុស្ស ដែលនេះគឺជាដំណើរការមួយមានការលំបាក និងលក្ខណៈស្មុគស្មាញ ។ សម្រាប់បុគ្គលមួយចំនួន ការទទួលបានការអប់រំដែលធ្វើឲ្យជីវិតប្រកបទៅដោយសេចក្តីថ្លៃថ្នូរ គឺជាបញ្ហាចម្បង ។ ចំណែកឯ បុគ្គលដទៃទៀត យល់ឃើញថា បញ្ហាចម្បង គឺការទទួលបានប្រាក់បៀវត្សរ៍ខ្ពស់សម្រាប់ផ្គត់ផ្គង់ខ្លួនឯង និងក្រុមគ្រួសារ ។ នៅក្នុងករណីខ្លះទៀត មនុស្សមួយចំនួនយល់ឃើញថា បញ្ហាចម្បងគឺការទទួលបានអាហារមិនគ្រប់គ្រាន់ ដែលអាចធ្វើឲ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរ និងសុខមាលភាពរបស់បុគ្គលទាំងនោះ ។

ដោយផ្អែកទៅលើ វិសាលភាពនៃច្បាប់សិទ្ធិមនុស្សអន្តរជាតិ ច្បាប់នេះត្រូវបានបង្កើតឡើងពីប្រភព និងប្រភេទច្បាប់ផ្សេងៗគ្នាជាច្រើន។ ច្បាប់ស្តីពីសិទ្ធិមនុស្ស អាចមានចែងនៅក្នុង សន្ធិសញ្ញាអន្តរជាតិ និងឯកសារមួយចំនួន រួមមាន សេចក្តីថ្លែងការណ៍ជាសកលស្តីអំពីសិទ្ធិមនុស្ស ជាដើម។ ច្បាប់ស្តីអំពីសិទ្ធិមនុស្ស ក៏អាចមានចែងនៅក្នុងរបាយការណ៍ និងសេចក្តីថ្លែងការណ៍ផ្សេងៗ ដែលបានបោះពុម្ពផ្សាយដោយអង្គការសហប្រជាជាតិ និងអង្គការផ្សេងៗ។

## សិទ្ធិក្នុងការទទួលបានអាហារគ្រប់គ្រាន់

សិទ្ធិក្នុងការទទួលបានអាហារគ្រប់គ្រាន់ ត្រូវបានលើកឡើងនៅក្នុង សេចក្តីថ្លែងការណ៍ជាសកលស្តីអំពីសិទ្ធិមនុស្ស របស់អង្គការសហប្រជាជាតិ នៅឆ្នាំ១៩៤៨ ដែលបានចែងថា "មនុស្សគ្រប់រូបមានសិទ្ធិទទួលបានលក្ខខណ្ឌរស់នៅសមរម្យ ទាំងសុខុមាលភាព និងសុវត្ថិភាពផ្ទាល់ខ្លួន និងក្រុមគ្រួសារ ដោយក្នុងនោះរាប់បញ្ចូលទាំងចំណីអាហារ។" សិទ្ធិនេះមានចែងយ៉ាងលម្អិតនៅក្នុង អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដែលជាឯកសារស្តីពីសិទ្ធិមនុស្ស ដ៏សំខាន់មួយរបស់អង្គការសហប្រជាជាតិ។

សិទ្ធិក្នុងការទទួលអាហារគ្រប់គ្រាន់ ក៏ត្រូវបានគាំទ្រដោយច្បាប់ផ្សេងៗ រួមមាន អនុសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិពលរដ្ឋនិងនយោបាយ អនុសញ្ញាស្តីអំពីការលុបបំបាត់ការរើសអើងស្ត្រី និងអនុ-សញ្ញាស្តីអំពីសិទ្ធិកុមារ ជាដើម។ មិនតែប៉ុណោះ សិទ្ធិក្នុងការទទួលបានអាហារគ្រប់គ្រាន់ ក៏ត្រូវបានចាត់ចូលជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ សិទ្ធិក្នុងការទទួលបានអាហារគ្រប់គ្រាន់ មានចែងនៅក្នុងមាត្រា១១ នៃអនុសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដែលតម្រូវឲ្យប្រទេសដែលជាហត្ថលេខីទាំងអស់ "ទទួលស្គាល់សិទ្ធិរបស់បុគ្គលគ្រប់រូបក្នុងការទទួលបានលក្ខខណ្ឌរស់នៅសមរម្យផ្ទាល់ខ្លួន និងក្រុមគ្រួសារ ដោយរាប់បញ្ចូលទាំងការទទួលបានអាហារគ្រប់គ្រាន់ និងសិទ្ធិជាមូលដ្ឋានក្នុងការរួចផុតពីភាពអត់ឃ្លាន។" ជាសរុប សិទ្ធិក្នុងការទទួលបានអាហារគ្រប់គ្រាន់ ត្រូវបានបង្កើតឡើងចេញពី សិទ្ធិពីរផ្សេងគ្នា ទីមួយៈ សិទ្ធិជាទូទៅក្នុងការទទួលបានអាហារគ្រប់គ្រាន់ ក្រោមទម្រង់ជាសន្តិសុខស្បៀងអាហារជាមូលដ្ឋាន និង ទីពីរៈ សិទ្ធិជាមូលដ្ឋានក្នុងការរួចផុតពីភាពអត់ឃ្លាន។

យោងតាមគោលការណ៍ច្បាប់ស្តីអំពីសិទ្ធិមនុស្ស ប្រទេសហត្ថលេខី នៃអនុសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ មានកាតព្វកិច្ចក្នុងការធានាឲ្យបានថា សិទ្ធិជាមូលដ្ឋានក្នុងការរួចផុតពីភាពអត់ឃ្លាន ត្រូវបានអនុវត្ត។ មិនតែប៉ុណ្ណោះ ប្រទេសហត្ថលេខីទាំងអស់ ត្រូវតែបំពេញ

សកម្មភាពផ្សេងៗមួយចំនួន ក្នុងការសំរេចឲ្យបាននូវគោលដៅរយៈពេលវែង នៃការធានាសន្តិសុខស្បៀងអាហារ សម្រាប់ប្រជាជននៅក្នុងប្រទេសរបស់ខ្លួន ដើម្បីចូលរួមបញ្ឈប់បញ្ហាកង្វះស្បៀងអាហារនៅទូទាំងសកលលោក ។ សិទ្ធិជាមូលដ្ឋាននៃការរួចផុតពីភាពអត់ឃ្លាន មិនអាចត្រូវបានមិនអើពើនោះទេ បើទោះបីជា ស្ថិតក្នុងស្ថានភាពគ្រោះធម្មជាតិ ឬគ្រោះមហន្តរាយផ្សេងៗក៏ដោយ ។

ការធានាទៅលើ សិទ្ធិជាមូលដ្ឋានក្នុងការរួចផុតពីភាពអត់ឃ្លាន មិនមែនត្រឹមតែជាការផ្តល់អាហារក្នុងកម្រិតអប្បបរិមាដើម្បីរស់តែប៉ុណ្ណោះទេ អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិ ទៅលើសិទ្ធិទទួលបានអាហារគ្រប់គ្រាន់ បានលើកឡើងអំពីចំនុចសំខាន់ក្នុងធានានូវ សិទ្ធិក្នុងការទទួលបានអាហារគ្រប់គ្រាន់ថា៖

> បុគ្គលគ្រប់រូបត្រូវបានធានាថា មានសិទ្ធិក្នុងការចិញ្ចឹមខ្លួនឯង មិនត្រឹមតែអាចទទួលបានអាហារនោះទេ ថែមទាំងមានសិទ្ធិក្នុងការស្វែងរក ផលិត ឬដាំដុះស្បៀងអាហារដោយខ្លួនឯង និងមានសិទ្ធិក្នុងការទិញចំណីអាហារដែលខ្លួនត្រូវការ ។

គណៈកម្មាធិការនៃអង្គការសហប្រជាជាតិស្តីអំពីសិទ្ធិសង្គម និងវប្បធម៌ បានលើកឡើងថា "សិទ្ធិក្នុងការទទួលបានអាហារគ្រប់គ្រាន់ សំដៅទៅលើ" ចំណីអាហារត្រូវតែអាចរកបានទាំងបរិមាណ និងគុណភាព ដើម្បីធានាថាបុគ្គលគ្រប់រូបទទួលបានចំណីអាហារគ្រប់គ្រាន់ ។ មិនតែប៉ុណ្ណោះ ចំណីអាហារទាំងនោះ ត្រូវតែឆ្លើយតបទៅនឹងអ្វីដែលជាវប្បធម៌របស់ប្រជាពលរដ្ឋ ហើយត្រូវធានាថា ការទទួលបានចំណីអាហារគ្រប់គ្រាន់ មិនបានប៉ះពាល់សិទ្ធិដទៃទៀត ។

ដូច្នេះ តម្រូវការចាំបាច់ក្នុងការអនុវត្តសិទ្ធិទទួលបានអាហារគ្រប់គ្រាន់ តម្រូវឲ្យរដ្ឋាភិបាលនៃប្រទេសហត្ថលេខី ចាត់វិធានការជាបន្ទាន់ ដើម្បីធានាថា ប្រជាពលរដ្ឋរបស់ខ្លួនអាចទទួលបានអាហារគ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់តម្រូវការរបស់ខ្លួន ព្រមទាំងចាត់វិធានការជាបន្តបន្ទាប់ ដើម្បីពង្រឹងការផ្គត់ផ្គង់ចំណីអាហារទាំងក្នុងស្រុក និងក្រៅស្រុក ។

បើយោងតាមអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រសិនបើ ប្រទេសណាមួយ "មិនអាចធានាថា ប្រជាជនខ្លួនអាចទទួលបានការផ្គត់ផ្គង់ចំណីអាហារក្នុងកម្រិតអប្បបរិមាដើម្បីជៀសផុតពីការអត់ឃ្លាន" ប្រទេសនោះនឹងត្រូវបានចាត់ទុកថា បានរំលោភទៅលើសិទ្ធិក្នុងការទទួលបានអាហារគ្រប់គ្រាន់ ។ ជាងនេះទៅទៀត ប្រទេសមួយអាចប្រកែកចំពោះការចោទប្រកាន់នេះបាន ប្រសិនបើ "ប្រទេសនោះជួបប្រទះនូវបញ្ហាកង្វះធនធាន ដែលមិនអាចផ្គត់ផ្គង់ចំណីអាហារបាន

គ្រប់គ្រាន់ដោយខ្លួនឯង ។ មិនតែប៉ុណ្ណោះ រដ្ឋាភិបាលនៃប្រទេសនោះបានប្រើប្រាស់រាល់ធនធានដែលខ្លួនមាន ដើម្បីបំពេញកាតព្វកិច្ចរបស់ខ្លួនដោយអស់ពីសមត្ថភាព ។»

## សិទ្ធិទទួលបានអាហារគ្រប់គ្រាន់នៅប្រទេសកម្ពុជា និងកេរ្តិ៍ដំណែលរបស់ខ្មែរក្រហម

ខណៈដែលសិទ្ធិក្នុងការទទួលបានអាហារគ្រប់គ្រាន់ ត្រូវបានយកមកពិនិត្យពិច័យក្នុងបរិបទនៃការអត់ឃ្លានដែលបានកើតមានឡើងក្នុងរបបខ្មែរក្រហម វាបានបញ្ជាក់យ៉ាងច្បាស់ថា រដ្ឋាភិបាលខ្មែរក្រហម ពិតជាបរាជ័យក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួន ដើម្បីធានាថាប្រជាពលរដ្ឋរបស់ខ្លួនរួចផុតពីការអត់ឃ្លាន ។ បើទោះបីជា ប្រទេសកម្ពុជាមិនមែនជាប្រទេសហត្ថលេខី នៃអនុសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ រហូតដល់ ឆ្នាំ១៩៩២ ក៏ដោយ សិទ្ធិជាមូលដ្ឋានរបស់ប្រជាពលរដ្ឋក្នុងការទទួលបានលក្ខខណ្ឌរស់នៅសមរម្យ ត្រូវបានចែងយ៉ាងច្បាស់នៅក្នុង សេចក្តីថ្លែងការណ៍ជាសាកលស្តីអំពីសិទ្ធិមនុស្ស ដែលបានបង្ហាញថា ខ្មែរក្រហមពិតជាបានរំលោភ សេចក្តីថ្លែងការណ៍នេះ ចន្លោះពី ឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ក្នុងរូបភាពផ្សេងៗជាច្រើន ដោយរួមមានការបង្កើតឲ្យមានលក្ខខណ្ឌនៃការអត់ឃ្លានរីករាលដាលនៅទូទាំងប្រទេស ។

ប្រសិនបើ ខ្មែរក្រហមបានចុះហត្ថលេខាលើអនុសញ្ញាអន្តរជាតិស្តីអំពី សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដែលបានព្រាងឡើងនៅក្នុងឆ្នាំ១៩៦៦ នោះខ្មែរក្រហមនឹងរំលោភបំពានទៅលើកាតព្វកិច្ចរបស់ខ្លួនទៅលើអនុសញ្ញានោះ ។ ជាបឋម ខ្មែរក្រហមមិនអាចយកលេសមិនផ្តល់អាហារគ្រប់គ្រាន់ ឬក្នុងចំនួនអប្បបរមា ទៅឲ្យប្រជាពលរដ្ឋនោះទេ បើទោះបីជា ស្ថានភាពកង្វះស្បៀងអាហារបានបន្សល់មកពីរបប លន់ នល់ ក៏ដោយ ។ មិនតែប៉ុណ្ណោះ ខ្មែរក្រហមក៏មិនអាចយកកត្តាគ្រោះធម្មជាតិ មកធ្វើជាលេស ថាខ្លួនមិនអាចបំពេញតម្រូវការចំណីអាហាររបស់ប្រជាពលរដ្ឋបាននោះទេ ។ ជាងនេះទៅទៀត ប្រសិនបើប្រទេសមួយចង់ធ្វើការបដិសេធថា ខ្លួនមិនមានធនធានគ្រប់គ្រាន់ ដើម្បីផ្គត់ផ្គង់ចំណីអាហារគ្រប់គ្រាន់ដល់ប្រជាជន លុះត្រាតែរដ្ឋាភិបាលនៃប្រទេសនោះ អាចបង្ហាញឲ្យឃើញថា ខ្លួនពិតជាបានខិតខំប្រឹងប្រែងប្រើប្រាស់ធនធានទាំងអស់ដែលមាន ដើម្បីចិញ្ចឹមប្រជាពលរដ្ឋរបស់ខ្លួន ។ ហេតុដូច្នេះ ខ្មែរក្រហមមិនអាចបដិសេធបានទេថា ខ្លួនបានចំណាយធនធានដែលមានទាំងអស់ ដើម្បីផ្គត់ផ្គង់ដល់ប្រជាពលរដ្ឋ ។ ផ្ទុយទៅវិញ ខ្មែរក្រហមបានធ្វើការនាំចេញផលិតផលស្បៀងយ៉ាងច្រើន នៅក្នុងអំឡុងពេលនៃការកាន់អំណាចរបស់ខ្លួន បើទោះបីជាស្ថានភាពនៃការអត់ឃ្លានបានរាលដាលនៅគ្រប់ទីកន្លែងក៏ដោយ ។

ជាសរុប ខ្មែរក្រហមពិតជាបរាជ័យក្នុងការបំពេញកាតព្វកិច្ចក្នុងការគោរពសិទ្ធមនុស្ស ដោយរាប់បញ្ចូលទាំងកាតព្វកិច្ចក្នុងការធានាឲ្យបានថា ប្រជាជនខ្លួនអាចទទួលបានអាហារគ្រប់គ្រាន់ ដើម្បីរស់រានមានជីវិត ។ ដូចដែលបានលើកឡើងនៅក្នុងវគ្គមុនៗនៃកម្មវិធីវិទ្យុនេះរួចមកហើយ ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរ ទៅលើសិទ្ធិទទួលបានអាហារគ្រប់គ្រាន់របស់ប្រជាជនស៊ីវិលនៅក្នុងរបបខ្មែរក្រហមហាក់ដូចជាបានរួចផុតពីការចោទប្រកាន់ទាក់ទងទៅនឹងការរំលោភសិទ្ធិមនុស្ស ហើយបែរជាត្រូវចោទពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិទៅវិញ ។

ជាចុងបញ្ចប់ យើងសង្កេតឃើញថាកេរ្តិ៍ដំណែលដែលបានបន្សល់ទុកពីការអត់ឃ្លាន ដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហម នៅតែបន្តកើតមាននៅក្នុងសង្គមកម្ពុជានាពេលបច្ចុប្បន្ន ។ ប្រជាជនកម្ពុជាភាគច្រើននៅតែត្រូវប្រឈមនឹងបញ្ហាកង្វះអាហារ សម្រាប់ផ្គត់ផ្គង់ខ្លួនឯង និងក្រុមគ្រួសារ ។ ជាលទ្ធផល សិទ្ធិក្នុងការទទួលបានអាហារគ្រប់គ្រាន់នៅតែមិនទាន់សម្រេចបាននៅក្នុងប្រទេសកម្ពុជានៅឡើយ បើទោះបីជា ប្រទេសកម្ពុជាបានចុះហត្ថលេខាលើអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ជាង២០ឆ្នាំរួចមកហើយ ពោលគឺនៅក្នុង ឆ្នាំ១៩៩២ ។ ថ្វីបើប្រទេសកម្ពុជាបានខិតខំប្រឹងប្រែងដោះស្រាយបញ្ហាមួយចំនួនទាក់ទងទៅនឹងសិទ្ធិក្នុងការទទួលបានអាហារគ្រប់គ្រាន់ក៏ដោយ ក៏នៅមានប្រជាជនជាច្រើននាក់នៅតែប្រឈមនឹងបញ្ហាកង្វះស្បៀងអាហារដដែល ។ កង្វះខាតនៃសន្តិ-សុខក្នុងការធានាថា ប្រជាជនទាំងអស់ទទួលបានអាហារគ្រប់គ្រាន់ ដែលជាសិទ្ធិជាមូលដ្ឋានសម្រាប់រស់រានមានជីវិតបានបង្ហាញថា កេរ្តិ៍ដំណែលពីរបបខ្មែរក្រហមពិតជា បានប៉ះពាល់ដល់សង្គមកម្ពុជាបច្ចុប្បន្ន ។ ទោះបីជាយ៉ាងនេះក្តី តាមរយៈកិច្ចខិតខំប្រឹងប្រែងក្នុងការធ្វើកំណែទម្រង់ និងការស្វែងរកយុត្តិធម៌ចំពោះរបួសពីអតីតកាល ប្រទេសកម្ពុជានឹងអាចទទួលបានស្ថេរភាព និងសន្តិសុខស្បៀងអាហារនាពេលអនាគតមិនខាន ។

*(ជាបន្តទៅនេះ យើងខ្ញុំសូមលើកយកបទសម្ភាសន៍ជាមួយអ៊ំប្រុស រ៉ុង ដែន អំពីជីវិតរបស់គាត់នៅក្នុងរបបខ្មែរក្រហម ។ សម្ភាសដោយ គីម ឡេង និង ម៉ៅ ច័ន្ទដាលី កាលពីថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៣ នៅ ខេត្តកែប ។ )*

<u>រ៉ុង ដែន</u>

ខ្ញុំឈ្មោះ រ៉ុង ដែន អាយុ៥៤ ។ ជំនាន់ ប៉ុល ពត ខ្ញុំនៅឃុំកំពង់ត្រឡាច ។ ខ្ញុំមិនត្រូវបានជម្លៀសទៅណាទេ ។ ដល់ឆ្នាំ១៩៧៥ ខ្ញុំបានបែកចេញពីម៉ែឪ ។ បើគិតទាំងឪពុកម្តាយ និងបងប្អូន ទាំងអស់៧

នាក់ៗ ខ្ញុំមានអាយុ ១៦ឆ្នាំ នៅឆ្នាំ១៩៧៤ៗ នៅពេលនោះ ខ្ញុំទៅធ្វើការនៅក្នុងកងចល័ត នៅកោះស្វា ទៅវែកដី លើកទំនប់ ជីកប្រឡាយ និងធ្វើស្រែ ចាប់ពីម៉ោង៦ ដល់ម៉ោង១១ និងចាប់ពីម៉ោង១ ដល់ម៉ោង៥ៗ ជីវភាពមិនបានគ្រប់គ្រាន់ទេៗ ហូបតែបបរៗ សម័យនោះ ការហូបចុកមិនបានពេញលក្ខណៈទេ ម្នាក់មួយវែកៗ ខ្ញុំមិនដែលបានបាយហូបពេញពោះទេ កាលដែលខ្ញុំនៅធ្វើការនៅក្នុងកងចល័តៗ ការឈឺថ្កាត់ក៏មានច្រើនៗ មានអ្នកខ្លះបានស្លាប់ ហើយមានអ្នកខ្លះទៀតនៅរស់ៗ

<u>ដាលី</u>ៈ ពេលដែលអ៊ំធ្វើការ អ៊ំធ្លាប់ឃើញគេវ៉ៃដំឬក៏អត់ទេ?

<u>ផែន</u>ៈ ពេលខ្លះមានមនុស្សគ្រោះថ្នាក់ពេលធ្វើការៗ ធ្លាប់មានអ្នកដែលស្លាប់ដោយសារតែដីបាក់ធ្លាក់កិនពីលើ នៅពេលដែលមនុស្សកំពុងកាយដីៗ មនុស្សមួយចំនួនបានដួលស្លាប់នៅពេលដែលកំពុងតែវែកដី ដោយសារតែអស់កម្លាំងៗ មនុស្សមួយចំនួនទៀតស្លាប់ ដោយសារតែទៅមន្ទីរពេទ្យមិនទាន់ៗ មនុស្សស្លាប់ច្រើនណាស់ៗ ជួនកាលមានបាត់មនុស្សនៅពេលយប់ៗ ខ្ញុំមិនដឹងថា មនុស្សទាំងនោះត្រូវបានយកទៅទីណានោះទេៗ មនុស្សបាត់ខ្លួនរៀងរាល់ថ្ងៃៗ ប៉ុន្តែ ខ្ញុំមិនហ៊ានសួរដេញដោលពីការបាត់ខ្លួននោះទេៗ ខ្ញុំគិតតែធ្វើការងារៗ ខ្ញុំខ្លាចថា ខ្លួនខ្ញុំនឹងមិនមានសេចក្តីសុខ ប្រសិនបើខ្ញុំមិនប្រឹងប្រែងធ្វើការៗ

<u>ដាលី</u>ៈ អ៊ំមានដឹងអំពីមូលហេតុនៃការបាត់ខ្លួនទេ?

<u>ផែន</u>ៈ ខ្ញុំដឹងខ្លះៗដែរ ប៉ុន្តែ ខ្ញុំមិនហ៊ាននិយាយទេនៅពេលនោះៗ មុនស្សដែលបានបាត់ខ្លួន អាចបណ្តាលមកពីការទាស់ពាក្យសម្តី ឬធ្វើការងារមិនពេញលក្ខណៈ ឬខ្ជិលច្រអូសៗ ជាងនេះទៅទៀតអ្នកដែលមានបងប្អូនធ្លាប់ធ្វើការនៅក្នុងរបប លន់ នល់ ក៏មិនត្រូវបានទុកចិត្តនោះទេៗ ចំណែកឯអ្នកដែលនៅរស់ ត្រូវតែចេះលាក់ប្រវត្តិរបស់ខ្លួនៗ

<u>ឡេង</u>ៈ ចំពោះជនរងគ្រោះដែលត្រូវដីបាក់ស្លាប់នៅពេលលើកទំនប់ តើអង្គការបានធ្វើអ្វីទេចំពោះអ្នកស្លាប់?

<u>ផែន</u>ៈ ជនដែលស្លាប់នោះត្រូវបានយកទៅកប់ៗ ចំណែកឯ ឪពុកម្តាយរបស់ជនរងគ្រោះ ត្រូវបានជូនដំណឹងអំពីការស្លាប់តែប៉ុណ្ណោះ មិនមានពិធីបុណ្យត្រូវបានរៀបចំនោះទេៗ ខ្មែរក្រហមមិនមានជំនឿខាងសាសនាអ្វីនោះទេៗ លុះដល់ពេលដែលខ្ញុំធំពេញវ័យ ខ្ញុំត្រូវបានជ្រើសរើសឲ្យធ្វើជាកងទ័ពៗ ពេលខ្ញុំទៅធ្វើទ័ព ខ្ញុំមិនសូវបានជួបមុខឪពុកម្តាយខ្ញុំនោះទេៗ ខ្ញុំទៅបម្រើទ័ពប្រហែលជាបីឆ្នាំ ទើបកងទ័ពវៀតណាមចូលមកដល់ៗ នៅក្នុងជួរកងទ័ព ខ្ញុំមានឋានៈជា ពលទោៗ ធ្វើជាកងទ័ពក៏ជួបការលំបាកដែរៗ កងទ័ពអាចនឹងស្លាប់ដោយមិនដឹងខ្លួន ដោយសារតែការវ៉ៃច្បាំងគ្នាកើតឡើងជារៀងរាល់ថ្ងៃៗ ពេលនោះ ខ្ញុំប្រចាំការនៅកោះដញ្ចុះៗ កងទ័ពមិនមានពេលវេលាសម្រាកត្រឹមត្រូវនោះទេៗ

កងទ័ពត្រូវតែប្រុងប្រយ័ត្នគ្រប់ពេលវេលា បើមិនដូច្នេះទេ នឹងត្រូវភាគីម្ខាងទៀតសម្លាប់ ។ ក្នុងអំឡុងពេលដែលខ្ញុំបម្រើក្នុងជួរកងទ័ព ខ្ញុំធ្លាប់បានលួចមកលេងផ្ទះតែម្តងនោះទេ ។

ឡេង: អ៊ំលួចមកលេងផ្ទះអញ្ចឹង បើខ្មែរក្រហមដឹង តើខ្មែរក្រហមនឹងធ្វើអ្វីចំពោះអ៊ំ?

ផែន: ពួកខ្ញុំចែកវេនគ្នាលួចមកលេងផ្ទះម្នាក់ម្តង ប៉ុន្តែ ខ្ញុំមិនអាចសម្រាកនៅផ្ទះនៅពេលយប់នោះទេ ។ ប៉ុន្តែ ប្រសិនបើការងាររវល់ ខ្ញុំមិនហ៊ានលួចចេញទេ ។ ចំពោះរឿងរ៉ាវនៃការសម្លាប់នៅតាមស្រុកភូមិ កងទ័ពមិនសូវជាដឹងប៉ុន្មានទេ ។

ដាលី: ខ្មែរក្រហមធ្លាប់បង្ហាត់ក្មេងៗឲ្យក្លាយជាកងទ័ពដែរឬទេ?

ផែន: មាន ។

ដាលី: ខ្មែរក្រហមបង្ហាត់ក្មេងៗទាំងនោះដោយរបៀបណាដែរ?

ផែន: ក្មេងៗត្រូវបានបែងចែកឲ្យនៅក្នុងកងកុមារ ។ កុមារទាំងអស់នោះ ត្រូវបានរដ្ឋចិញ្ចឹម និងមានមេកងដឹកនាំ ពន្យល់ពីតួនាទី ។ ដល់ពេលដែលកុមារទាំងអស់នោះធំពេញវ័យ ទើបខ្មែរក្រហមបញ្ជូនឲ្យទៅធ្វើជាកងទ័ព ។

ឡេង: នៅជំនាន់ខ្មែរក្រហមអ៊ំរៀបការហើយឬនៅ?

ផែន: នៅទេ ។

ឡេង: អ៊ំមានដឹងពីការរៀបការនៅក្នុងរបបខ្មែរក្រហមដែរឬទេ?

ផែន: ខ្ញុំដឹង ។ ការរៀបការនៅសម័យខ្មែរក្រហម មិនដូចការរៀបការសម័យបច្ចុប្បន្ននោះទេ ។ ខ្ញុំសុំលើកយកបទពិសោធន៍ ដែលខ្ញុំជួបប្រទះពេលដែលខ្ញុំធ្វើការនៅក្នុងកងចល័ត នៅកោះស្លា ។ ការរៀបការមិនមែនត្រូវបានរៀបចំឡើងម្តងមួយគូនោះទេ យ៉ាងហោចណាស់ ២០គូក្នុងពេលតែមួយ ។ យុវជន និងយុវនារី ត្រូវបានឲ្យអង្គុយតំរៀបជួរគ្នា ។ យុវជន យុវនារីខ្លះ បានស្គាល់មុខ គូរបស់ខ្លួន យុវជន យុវនារីខ្លះទៀត មិនបានស្គាល់មុខ គូរបស់ខ្លួននោះទេ ។ យុវជន យុវនារីខ្លះ មានការខ្មាសអៀន ហើយមិនហ៊ានងើបមុខមើលគូរបស់ខ្លួននោះទេ ។ បន្ទាប់ពីរៀបការហើយ ប្តីប្រពន្ធថ្មីទាំងនោះមិនមានផ្ទះសម្បែងត្រឹមត្រូវនោះទេ ។ យុវជន និងយុវនារី រស់នៅដាច់ដោយឡែកពីគ្នា ទៅតាមកងរៀងៗខ្លួន ។ បន្ទាប់ពីរៀបការរួច ប្តីប្រពន្ធដែលបានរៀបការរួច ត្រូវបានអនុញ្ញាតឲ្យសម្រាកមួយអាទិត្យ ។ បន្ទាប់មក ប្តីប្រពន្ធដែលទើបរៀបការរួច ត្រូវត្រឡប់ទៅធ្វើការនៅក្នុងកងរបស់ខ្លួនវិញ ។

ដាលី: នៅពេលដែលកងទ័ពវៀតណាមបានចូលមកដល់ តើអ៊ំទៅរស់នៅទីណាដែរ?

ផែន: ពេលនោះ ខ្ញុំបានរត់ចេញពីដាយផែន ទៅពេជនិល នៅក្នុងព្រៃ ។ ខ្ញុំនៅទីនោះអស់រយៈពេល ៦ខែ ។ ខ្ញុំរត់តាមកងទ័ពដទៃទៀត ។ ខ្មែរក្រហមបានប្រាប់ថា បើសិនជាយើងត្រឡប់ទៅផ្ទះវិញ

កងទ័ពវៀតណាមនឹងមិនទុកយើងនោះទេ ដោយសារតែយើងធ្លាប់ធ្វើជាកងទ័ព ។ នៅពេលរត់ទៅនោះ កងទ័ពមួយចំនួនក៏បានស្លាប់បាត់បង់ជីវិត ។

ឡេង: តើក្រុមគ្រួសាររបស់អ៊ំនៅជួបជុំគ្នាទេ នៅពេលដែលអ៊ំត្រឡប់មកវិញ?

ដែន: ពេលមកដល់ភ្លាម បងប្អូនខ្ញុំមិនទាន់បានជួបជុំគ្នាទេ ដោយសារតែ អ្នកទាំងអស់នោះ ត្រូវបានចាត់តាំងឲ្យធ្វើការនៅក្នុងកងខុសគ្នា ។ ខ្ញុំបានជួបតែឪពុកម្ដាយរបស់ខ្ញុំ ។

ឡេង: តើបងប្អូនរបស់អ៊ំនៅរស់ទាំងអស់ទេ?

ដែន: បាទ ។ នៅរស់ទាំងអស់គ្នា ។

នេះគឺជាចុងបញ្ចប់នៃការផ្សាយវគ្គទី៩ នៃកម្មវិធីវិទ្យុរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលពិនិត្យពិច័យទៅលើការអត់ឃ្លាននៅក្នុងរបបខ្មែរក្រហម ។ ការផ្សាយនៅក្នុងវគ្គទី១០ ដែលជាវគ្គចុងក្រោយនៃកម្មវិធីវិទ្យុនេះ យើងខ្ញុំនឹងធ្វើការសង្ខេបពីបញ្ហាមួយចំនួនដែលទាក់ទងទៅនឹង យុត្តិធម៌ និងការអត់ឃ្លាននៅក្នុងរបបខ្មែរក្រហម ។

មជ្ឈមណ្ឌលឯកសារកម្ពុជា សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះប្រិយមិត្តអ្នកស្ដាប់ដែលបានតាមដានស្ដាប់ការផ្សាយរបស់យើងខ្ញុំ ។ មជ្ឈមណ្ឌលឯកសារកម្ពុជា សូមថ្លែងអំណរគុណចំពោះស្ថានីយវិទ្យុផ្សាយសម្លេងសហរដ្ឋអាមេរិក-រាជធានីភ្នំពេញ ដែលបានផ្ដល់ស្ទូឌីយោថតសម្លេង ។

កម្មវិធីវិទ្យុនេះឧបត្ថម្ភដោយ នាយកដ្ឋានកម្មវិធីសកលនៃការិយាល័យប្រជាធិបតេយ្យ សិទ្ធិមនុស្ស និង ពលកម្ម របស់ក្រសួងការបរទេសសហរដ្ឋអាមេរិក ។

កម្មវិធីវិទ្យុនេះ ចាក់ផ្សាយរៀងរាល់ថ្ងៃអាទិត្យ តាមរយៈវិទ្យុជាតិកម្ពុជា AM918 KHz រាជធានីភ្នំពេញ វេលាម៉ោង ៩ព្រឹក និង ម៉ោង៧និង៣០នាទីល្ងាច ។ វិទ្យុខេត្តកំពត FM93.25 វេលាម៉ោង៧ព្រឹក និងម៉ោង៧ល្ងាច ។ វិទ្យុខេត្តព្រះវិហារ FM99 វេលាម៉ោង៧និង៣០នាទីព្រឹក និង ម៉ោង៤រសៀល ។ វិទ្យុខេត្ត បាត់ដំបង FM103.25 វេលាម៉ោង៨ព្រឹក និង ម៉ោង៤រសៀល ។